**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**តាងនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងខេត្តកំពង់ឆ្នាំង
លេខៈ១០(ង)
ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ២២៧
ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧

បើកសវនាការជាសាធារណៈ នៅសាលសវនាការ សាលាដំបូងខេត្តកំពង់ឆ្នាំង។ បើកសវនាការនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ រសៀល។ ប្រកាសសាលក្រមនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៨ រសៀល ។

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

១-លោកស្រី ....ជាប្រធានក្រុមប្រឹក្សា

២-លោក .... ជាចៅក្រមប្រឹក្សា

៣-លោក .... ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោកស្រី .... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

-លោក ................ក្រឡាបញ្ជីសាលាដំបូង

ដើម្បីជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌលេខ២២៧ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ

-ឈ្មោះ...............ភេទប្រុស អាយុ៣៣ ឆ្នាំជាតិខ្មែរ មុខរបរនៅផ្ទះ កើតនៅភូមិរលាំងទាក ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ទីលំនៅនៅភូមិត្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង។

ឪពុកឈ្មោះ.........ម្ដាយឈ្មោះ.......លែងលះគ្នាទោសពីមុនគ្មាន។ (ឃុំខ្លួន០៥-០៤-២០១៧) ។

ជាប់ចោទពីបទៈ ឃាតកម្ម ប្រព្រឹត្តនៅភូមិត្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី៣០-០៣-២០១៧។ បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

ដែលមានលោក.....ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទខាងលើ។

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ២៦៤ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពត។

## ដើមបណ្ដឹងរដ្ឋប្បវេណី

ឈ្មោះ........ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិបឹងព្រីង ឃុំបឹងព្រីង ស្រុកថ្មគោល ខេត្តបាត់ដំបង។

## អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី៣០-០៣-២០១៧ វេលាម៉ោង០៨ និង៣០នាទី នៅចំណុចផ្ទះឈ្មោះ.......បានយកពូថៅកាប់លើឈ្មោះ......បងថ្លៃដោយមានទំនាស់ពាក្យសម្ដីជាមួយគ្នា ហើយត្រូវបានឈ្មោះ.......ត្រូវជាបងស្រីបានទៅជួយឃាត់ ហើយត្រូវបានឈ្មោះ.......កាប់ទៅលើឈ្មោះ........បណ្ដាលឱ្យស្លាប់ទាំងពីរនាក់តែម្ដង។

## នាពេលសវនាការ

ក្រោយពីបាន៖

-ស្ដាប់ចម្លើយជនជាប់ចោទឈ្មោះ......

-ស្ដាប់ចម្លើយសាក្សីឈ្មោះ........

-ស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ......

-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ស្តាប់ការកត់សម្គាល់ខ្លីៗ និងជាសំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងនិងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១-តាមរបាយការណ៍ស៊ើបអង្កេតសន្និដ្ឋាន ដោយមន្ត្រីនគរបាលយុត្តិធម៌ មានលក្ខណៈគ្រប់គ្រាន់អាចបញ្ជាក់បាន ថាពិតជាមានការសម្លាប់កាលពីថ្ងៃទី៣០-០៣-២០១៧ នៅត្រង់ចំណុចភូមិត្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បង្ករឡើងដោយឈ្មោះ........បានយកពូថៅកាប់ទៅលើជនរងគ្រោះឈ្មោះ........និងឈ្មោះ........ បណ្តាលឱ្យស្លាប់ប្រាកដមែន។

២-ក្នុងអង្គសវនាការ

-ជនជាប់ចោទឈ្មោះ.....បានឆ្លើយថា នៅថ្ងៃកើតហេតុនោះខ្លួនឱ្យបងថ្លៃជូនទៅវត្ត គាត់មិនជូនទៅទេ គាត់ឱ្យខ្លួនដើរទៅតែខ្លួនមិនខឹងទេ ខ្លួនដើរទៅសិតសក់ ហើយក៏និយាយជាមួយគាត់តទល់គ្នាហើយប្រុងដើរទៅពាក់អាវ គាត់ទះថ្វាស ខ្លួនមួយដៃមិនឱ្យខ្លួនទៅ។ ថ្ងៃនោះនៅផ្ទះតែ៣នាក់ទេ បងខ្លួនប្តីគាត់និងខ្លួន ។ខ្លួនឃើញពូថៅក៏កាប់គាត់តែម្តង បងស្រីខ្លួនចូលមកនិយាយថាកន្លែងនឹងមានដាក់កាមេរ៉ា និងថតសម្លេង រួចខ្លួនបានទាញពូថៅកាប់បងស្រីខ្លួនតែម្តង ពេលកាប់ បងស្រីខ្លួនមិនមានបំណងទេ ពេលកាប់ហើយខ្លួនហត់ពេកក៏អង្គុយទៅ។ ខ្លួនយកពូថៅកាប់បងថ្លៃចំនួន៧ពូថៅ ក្បាល៥ ពូថៅ ពោះ១និងទ្រូង១កាប់បងស្រីខ្លួនឈ្មោះ....ត្រូវចំក្បាល គាត់ស្លាប់ទាំងពីរនាក់។ ខ្លួនដឹងថាកាប់នោះវាខុសច្បាប់។

-តាមចម្លើយរបស់សាក្សីឈ្មោះ......ថ្ងៃកើតហេតុនោះ ខ្លួនមិនទៅកន្លែងកើតហេតុទេ។ កូនរបស់ខ្លួនស្លូតណាស់ មិនកាចអញ្ចឹងទេ គ្រាន់តែនិយាយច្រើន មានសភាពដូចពេលនេះ០៣ឆ្នាំហើយ។ខ្លួនដើររកគ្រូខ្មែរច្រើនកន្លែងហើយ ហើយ ខ្លួនបានទៅបើកថ្នាំនៅពេទ្យរុស្សីដែរ។ខ្លួនចេញពីផ្ទះបានពីរថ្ងៃកូនទៅបាត់ដំបងគេប្រាប់ថាកូនស្រីខ្លួននិងកូនប្រសារស្លាប់ ហើយពេលខ្លួនទៅដល់ផ្ទះ វាបាត់ពីផ្ទះទៅហើយ។ កូនខ្លួនធ្លាប់ជាប់ពន្ធនាគារ០៣ឆ្នាំម្តងហើយ។ពេទ្យរុស្សីថាវាសរសៃប្រសាទកម្រិតធ្ងន់ មានលិខិតបញ្ជាក់ និងសៀវភៅបើកថ្នាំ។

-ដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា នៅថ្ងៃទី៣០-០៣-២០១៧ វេលាម៉ោង១៣ និង៣០នាទី ខ្លួនកំពុងនៅផ្ទះឈ្មោះ.......បានទូរស័ព្ទមកខ្លួនថា បងថ្លៃខ្លួនឈ្មោះ......ត្រូវគេសម្លាប់នៅផ្ទះប្រពន្ធចុងគាត់ហើយខ្លួនបានតែទៅទាក់ទងសមត្ថកិច្ចនៅទីនោះ គេប្រាប់ខ្លួនថាបងថ្លៃខ្លួននិងប្រពន្ធចុងគាត់ ត្រូវប្អូនបង្កើតប្រពន្ធចុងជាអ្នកសម្លាប់។ ខ្លួនបានទាក់ទងទៅប្រពន្ធដើមគាត់យកសពគាត់ទៅធ្វើបុណ្យនៅស្រុកកំណើត។

-សាក្សីឈ្មោះ......បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា កាលពីថ្ងៃទី៣០-០៣-២០១៧ វេលាម៉ោង៨និង៣០នាទី ខ្លួនកំពុងធ្វើត្រីនៅក្រោមដើមស្វាយនៅផ្ទះ ស្រាប់តែឮមីងចាន់ថនហៅស្រែកថាអើមីអូន ខ្លួនក៏ងាកមើលឃើញគាត់នៅក្រោមដើមត្នោតក្បែរផ្ទះគាត់ ហើយរត់ចូលក្នុងផ្ទះគាត់វិញឮគាត់ស្រែកថាជួយប្តីខ្ញុំផង និងឃើញគាត់ចាប់ទាញប្អូនប្រុសគាត់ឈ្មោះ......ចេញមកមុខផ្ទះ ឃើញប្អូនគាត់មានកាន់ពូថៅនៅនឹងដៃ រួចឈ្មោះ.........រត់ចូលក្នុងផ្ទះហើយប្អូន គាត់ក៏រត់ស្ទុះទៅតាមក្រោយ ហើយបាត់សម្លេងឈឹងបានបន្តិចក្រោយមក ក៏ឃើញប្អូនគាត់ចេញមកវិញដើរជុំវិញផ្ទះពុំឃើញមានកាន់

អ្វីទេ រួចឃើញគាត់ដើរទៅពាងទឹងលាងសម្អាតខ្លួន រួចចូលក្នុងផ្ទះស្លៀកពាក់ខោអាវ ហើយដើរចេញទៅទិសខាងលិចបាត់។ បន្ទាប់មកខ្លួនបាននិយាយរឿងនេះប្រាប់យាយ ហើយគាត់នាំខ្លួនទៅផ្ទះមីងតូច ពេលទៅដល់ឃើញ មីងតូចនិងប្តីគាត់ត្រូវគេកាប់សម្លាប់ទាំងពីរនាក់ក្នុងផ្ទះ។

-តាមការបំភ្លឺរបស់សាក្សីឈ្មោះ........ដឹងថា នៅថ្ងៃទី៣០-០៣-២០១៧ វេលាម៉ោង៨និង៣០នាទី ខ្លួនកំពុងអង្គុយ លើគ្រែក្រោមដើមស្វាយនៅផ្ទះរបស់ខ្លួន បានឮសម្លេងស្រែកថា ជួយប្តីខ្ញុំផងៗហើយខ្លួនងាកមើលឃើញឈ្មោះ........ចាប់ ទាញប្អូនប្រុសគាត់ឈ្មោះ.......ចេញមកក្រៅផ្ទះនិងស្រែកយំយ៉ាងខ្លាំងហើយខ្លួនក៏ដើរចូលទៅក្នុងផ្ទះមិនដឹងឈ្លោះគ្នារឿង អីទេព្រោះមិនចាប់អារម្មណ៍បន្តិច ក្រោយមកខ្លួនក៏បានដើរទៅប្រាប់ឈ្មោះ.......និងឈ្មោះ.....រួចពួកគាត់នាំគ្នាដើរទៅមើល ឃើញប្តីប្រពន្ធទាំងពីរនាក់ស្លាប់បាត់ទៅហើយហើយខ្លួនក៏រាយការណ៍ទៅមេភូមិ និងប៉ុស្តិ៍សមត្ថកិច្ចតែម្តង។

-អំណានចម្លើយរបស់សាក្សីឈ្មោះ.......កាលពីថ្ងៃទី៣០-០៣-២០១៧ វេលាម៉ោងប្រហែល៨ ៣០នាទីខ្លួនកំពុង អង្គុយលេងផ្ទះមីងរបស់ខ្លួនឈ្មោះ......តូច នៅភូមិជាមួយគ្នា បានបន្តិច ខ្លួនក៏ជិះម៉ូតូទៅផ្ទះបងខ្លួននិងនៅក្បែរនោះ ស្រាប់តែឃើញឈ្មោះ......ជាប្អូនប្រុសរបស់ឈ្មោះ.....មកដល់ឃើញស្លៀកខោកីឡាមិនចាំពណ៌ និងពាក់អាវដៃខ្លីពណ៌ស បានសុំពឹងខ្លួនឱ្យឌុបជូនទៅផ្លូវជាតិលេខ៥ ម្តុំផ្សារត្រាច ខ្លួនក៏ព្រមពេលទៅដល់ឈ្មោះ.....ក៏ចុះមិនដឹងទៅណាទេ រួចខ្លួនក៏ជិះ ម៉ូតូត្រឡប់មកផ្ទះបងស្រីខ្លួនវិញ។ប្រហែលមួយម៉ោងក្រោយមកស្រាប់តែឮអ្នកភូមិឆ្អើលនិយាយថា **ចថ** និងប្តីរបស់គាត់ត្រូវគេកាប់សម្លាប់។

តាមចម្លើយសារភាពរបស់ជនជាប់ចោទ អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី ឃើញថានៅថ្ងៃកើតហេតុជនជាប់ចោទពិតជាបានយកពូថៅកាប់ទៅលើបងថ្លៃ និងបងស្រីបង្កើតបណ្ដាលឱ្យស្លាប់នៅនឹងកន្លែងប្រាកដមែន។ ទង្វើរបស់ជនជាប់ចោទ ត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើសដែលត្រូវផ្ដន្ទាទោសតាមមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

-លោកតំណាងអយ្យការ ធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ៖ ក្រោយពីបានស្ដាប់ការសួរដេញដោលក្នុងអង្គសវនាការ ឃើញថា កាលពីថ្ងៃទី៣០-០៣-២០១៧ពិតជាមានករណីឃាតកម្ម ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ.... ជនជាប់ ចោទបានសារភាពថាពិតជាបានកាប់ទៅលើបងថ្លៃឈ្មោះ......និងបងស្រីបង្កើតឈ្មោះ..........បណ្ដាលឱ្យស្លាប់ពិតមែន។ ដូច្នេះតំណាងអយ្យការសុំតម្កល់បទចោទនិងសុំឱ្យចៅក្រមផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

-លោកមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ធ្វើសេចក្ដីសន្និដ្ឋានការពារតាមរយៈអង្គសវនាការឃើញថាកូនក្ដីរបស់ខ្លួនមានស្មារតីច្របូកច្របល់ និយាយយកជាការមិនបាន ហើយម្ដាយបានអះអាងថាធ្លាប់យកទៅពេទ្យរុស្ស៊ីព្យាបាល។ ដូច្នេះសុំចៅក្រមចាត់របៀប និងធ្វើកោសល្យវិច័យទៅលើស្មារតីរបស់កូនក្ដីខ្លួនមុននឹងសម្រេចសេចក្ដី។

-ការសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលស្នើឱ្យតុលាការចាត់របៀបដើម្បីឱ្យអ្នកជំនាញ ធ្វើកោសល្យវិច័យទៅលើស្មារតីរបស់ជនជាប់ចោទនោះ តុលាការមិនឯកភាពនោះទេព្រោះថាក្នុងពេលសវនាការជនជាប់ ចោទអាចឆ្លើយបាននូវរាល់សំណួរ របស់ក្រុមប្រឹក្សាជំនុំជម្រះ តំណាងអយ្យការក៏ដូចជាមេធាវី ហើយចម្លើយនោះទៀតសោតមិនមានចម្លើយណាមួយដែលបញ្ជាក់ពីវិបល្លាសស្មារតីរបស់ជនជាប់ចោទ ដើម្បីឈានទៅដល់

ការធ្វើកោសល្យវិច័យនោះទេ ដោយជនជាប់ចោទបានឆ្លើយនូវរាល់សកម្មភាព របស់ខ្លួន ហើយជនជាប់ចោទក៏បានឆ្លើយដែរថា ខ្លួនដឹងថាសម្លាប់មនុស្សគឺខុសច្បាប់។

៣-ជនជាប់ចោទជានីតិជន ហើយបានប្រព្រឹត្តសកម្មភាពខាងលើ ដោយចេតនាយល់ដឹងគ្រប់គ្រាន់។

៣.១-មានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ....ពីបទឃាតកម្ម ប្រព្រឹត្តនៅភូមិត្រពាំងសំរោង ឃុំសង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំងកាលពីថ្ងៃទី៣០-០៣-២០១៧។បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

៣.២-គប្បីប្រកាសទណ្ឌកម្មលើជនជាប់ចោទចំនួន១០ឆ្នាំ (ដប់ឆ្នាំ) ដោយពិចារណាដល់ភាពធន់ស្រាលនៃសកម្មភាពល្មើស ផលប៉ះពាល់ និងព្យសនៈកម្ម ដែលកើតចេញពីអំពើល្មើស និងស្ថានភាពផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ដូចខាងក្រោម៖

-អំពើល្មើសរបស់ជនជាប់ចោទ បណ្តាលឱ្យជនរងគ្រោះ ដែលជាបងបង្កើតនិងបងថ្លៃបាត់បង់ជីវិតហើយសកម្មភាព ជនជាប់ចោទប្រព្រឹត្តបទដោយភាពក្លាហានដោយឃោរឃៅ អមនុស្សធម៌ តែជនជាប់ចោទបានសារភាពនូវរាល់ទង្វើររបស់ខ្លួន មិនបានបង្កផលវិបាកដល់តុលាការក្នុងការស្វែងរកការពិតនោះទេ។ ទង្វើទាំងនេះហើយ ដែលទាំឱ្យតុលាការផ្តន្ទាទោស ជនជាប់ចោទដូចក្នុងចំណុច៣.២ខាងលើ។

៤-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ........មិនបានទាមទារសំណងជំងឺចិត្តជនជាប់ចោទនោះទេ ដូច្នេះតុលាការមិនពិចារណាដើម្បីសម្រេចពីបញ្ហាសំណងរដ្ឋប្បវេណីទេ។

# សេចក្តីសម្រេច

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ.........ភេទប្រុស អាយុ៣៣ ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន១០ឆ្នាំ(ដប់ឆ្នាំ)

ពីបទៈឃាតកម្ម ប្រព្រឹត្តនៅភូមិត្រពាំងសំរោង ឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃ៣០-០៣-២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា១៩៩ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។